**Declassified to Public**
**12 June 2020**

លេខ៖ D307/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 16 / 11 / 2016
ម៉ោង (Time/Heure): 11:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦**

ភាសា ៖ **ខ្មែរ/អង់គ្លេស [អង់គ្លេសភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

# សេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន(២)

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**

សូ មូស្សេនី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ចេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉េន ពៅ

Linda BEHNKE
Laure DESFORGES
NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ នៅក្នុងសំណើសុំសេចក្តីអធិប្បាយទាក់ទងនឹងអង្គហេតុដែលត្រូវបានចោទ ដែលនឹងពុំត្រូវបានស៊ើបសួរបន្ថែម ("សំណើសុំយោបល់") ខ្ញុំបានជូនដំណឹងភាគីទាំងអស់អំពីគោលបំណងរបស់ខ្ញុំ ដែលនឹងមិនស៊ើបអង្កេតថែមទៀតលើអង្គហេតុមួយចំនួន[1]។

២. អោ អាន បានដាក់យោបល់នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៦[2] ហើយ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់យោបល់នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៦[3]។

៣. នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ នៅក្នុងសេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ[4]("សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរ") ខ្ញុំបានជូនដំណឹងភាគីទាំងអស់ថា ខ្ញុំនឹងមិនស៊ើបអង្កេតថែមទៀតលើអង្គហេតុដូចខាងក្រោមដែលបានចោទនៅក្នុងដីកាសេចក្តីសន្និដ្ឋានរបស់ ស.ព.អ ដែលជាបឋមបង្ហាញឲ្យឃើញថាអាចអនុវត្តវិធានផ្ទៃក្នុង ៦៦ ស្ទួន។

ក) **អង្គហេតុ ក៖** ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៅតំបន់ ៤២ និង ៤៣៖

- មន្ទីរសន្តិសុខទួលតាផ្គង[5]

---

[1]សំណុំរឿង ០០៤ ឯកសារ D307 *សំណើសុំសេចក្តីអធិប្បាយទាក់ទងនឹងអង្គហេតុដែលត្រូវបានចោទ ដែលនឹងពុំត្រូវបានស៊ើបសួរបន្ថែម* ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ កថាខណ្ឌ ៣ និង ៧។

[2]សំណុំរឿង ០០៤ ឯកសារ D307/1 *សារណារបស់ អោ អាន ឆ្លើយតបទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិស្នើសុំផ្តល់យោបល់ទាក់ទងនឹងអង្គហេតុដែលត្រូវបានចោទប្រកាន់មិនចាំបាច់ស៊ើបអង្កេតបន្ថែម* ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៦។

[3]សំណុំរឿង ០០៤ ឯកសារ D307/2 *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិស្នើសុំផ្តល់យោបល់ទាក់ទងនឹងអង្គហេតុដែលត្រូវបានចោទប្រកាន់មិនចាំបាច់ស៊ើបអង្កេតបន្ថែម* ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៦។

[4]សំណុំរឿង ០០៤ ឯកសារ D307/3 *សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ* ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦។ គួរកត់សម្គាល់ថា ការចោទប្រកាន់នានាគឺសំដៅលើអង្គហេតុមួយ។

[5]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៥០-៥១។

- មន្ទីរសន្តិសុខវត្តកណ្ដាល[6]
- មន្ទីរសន្តិសុខចម្ការស្វាយចន្ទី[7]
- មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក[8]
- មន្ទីរសន្តិសុខវត្តស្រង៉ែ[9]

ខ) **អង្គហេតុ ខ៖** ការចាប់ខ្លួន និងការស្លាប់ជនជាតិចាមនៅភូមិភាគបូព៌ា[10]

គ) **អង្គហេតុ គ៖** ការធ្វើទារុណកម្មនៅទួលបេង/វត្តអង្គញដី[11]

ឃ) **អង្គហេតុ ឃ៖** ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទុក្ខបុកម្នេញនៅវត្តភ្នំប្រុស[12]។

## II. ពិភាក្សា

៤. វិធាន ៦៦*ស្ទួន*(២) ចែងថា មុនពេលកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ខ្ញុំត្រូវជូនដំណឹងអំពីព័ត៌មានលម្អិតស្ដីពីគោលបំណងនៃការកាត់បន្ថយ ទៅសហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីដទៃទៀត ហើយភាគីទាំងអស់ នឹងមានពេល ១៥ ថ្ងៃដើម្បីដាក់សារណា។

៥. តាមសំអាងហេតុដូចបានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរ ខ្ញុំមានបំណងដកអង្គហេតុ ក, ខ, គ និង ឃ ចេញពីកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន* នៅពេលបិទកិច្ចស៊ើបសួរ។

៦. ខ្ញុំមានយោបល់ថា បន្ទាប់ពីដកចេញនូវអង្គហេតុ ក, ខ, គ និង ឃ នៅពេលបិទកិច្ចស៊ើបសួរ អង្គហេតុដែលនៅសេសសល់នឹងតំណាងឲ្យវិសាលភាពនៃដីកាសន្និដ្ឋាន តាមភូមិសាស្ត្រ ពេលវេលា និងអង្គសេចក្តីទាក់ទងនឹងលក្ខណៈ និងទំហំនៃឧក្រិដ្ឋកម្ម និងប្រភេទជនរងគ្រោះ។

---

[6]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៥២។

[7]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៣៤។

[8]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៥៣។

[9]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៤៩។

[10]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៤៥-៤៦។

[11]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៣០-៣៣។ ដីកាសន្និដ្ឋានទី ២ កថាខណ្ឌ ១១។ ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១-២។

[12]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៣០-៣១។

៧. ដូចខ្ញុំធ្លាប់បានបញ្ជាក់ពីមុនរួចហើយ វិធានផ្ទៃក្នុង ៦៦ *ស្ទួន* (៥) បញ្ជាក់ច្បាស់ថា នៅពេលដែលដកអង្គហេតុចេញ ភស្តុតាងពាក់ព័ន្ធនឹងអង្គហេតុដែលបានដកចេញទាំងនេះនៅតែអាចប្រើប្រាស់ជាមូលដ្ឋានបានឱ្យតែពាក់ព័ន្ធនឹងអង្គហេតុដែលនៅសេសសល់។

៨. ការដកចេញនូវអង្គហេតុ ក, ខ, គ និង ឃ នឹងមិនប៉ះពាល់ដល់ឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការចូលរួមកិច្ចស៊ើបសួរឡើយ។

**តាមសំអាងហេតុខាងលើ ខ្ញុំ៖**

៩. **ជូនដំណឹង** ភាគីទាំងអស់ អំពីគោលបំណងរបស់ខ្ញុំ <u>យោងតាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន*(២)</u> ក្នុងការដកអង្គហេតុ ក, ខ, គ និង ឃ ចេញពីកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន*។

១០. **អញ្ជើញ** ភាគីទាំងអស់ ដាក់សារណា ស្របតាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន* (២) ក្នុងរយៈពេល ១៥ ថ្ងៃចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងនេះ។

១១. **យល់ឃើញ** ថា ខ្ញុំនៅតែទទួលពិនិត្យអង្គហេតុទាំងអស់ខាងលើ ហើយសេចក្តីជូនដំណឹងនេះមិនប៉ះពាល់ដល់សមត្ថកិច្ចរបស់ខ្ញុំក្នុងការបើកកិច្ចស៊ើបសួរឡើងវិញលើអង្គហេតុទាំងនេះឡើយប្រសិនបើខ្ញុំសម្រេចថាមានមូលហេតុត្រូវធ្វើដូច្នេះ។

១២. **ជូនដំណឹង** ភាគីទាំងអស់ថា ការឆ្លើយតប និងសារណាតបទៅនឹងសារណារបស់ភាគីផ្សេងទៀតយោងតាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន* (២)នឹងមិនទទួលយកឡើយ។

ភ្នំពេញ ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**